ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ការផលិតសម្ភារពិសោធន៍
# និងវិធីសាស្ត្របង្រៀនពិសោធន៍

## មុខវិជ្ជាផែនដីវិទ្យា

ការប្រើប្រាស់ថវិកាដោយគម្រោងអភិវឌ្ឍ

វិស័យអប់រំមធ្យមសិក្សាទុតិយភូមិ ( USESDP )

រាជធានីភ្នំពេញ ឆ្នាំ២០២១

# មុខកថា

ទស្សនវិស័យនៃការអប់រំសតវត្សរ៍ទី២១ បានកំណត់យកការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាឌីជីថល ជាមូលដ្ឋានគន្លឹះក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដើម្បីឆ្លើយតបទៅនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជាឆ្នាំ២០៣០ និង២០៥០ ដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្ម។ ជាមួយគ្នានេះ ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំឆ្នាំ២០១៨-២០២៣ ដោយផ្ដោតលើការកែលម្អវិធីសាស្ត្របង្រៀន និងរៀន ការផលិតសម្ភារឧបទេស សម្ភារៈពិសោធ ការពិសោធ និងសម្ភារៈបណ្ណាល័យ ដើម្បីឆ្ពោះទៅរកគុណភាពអប់រំប្រកបដោយចីរភាពនៅមធ្យមសិក្សាទុតិយភូមិ ទូទាំងប្រទេសកម្ពុជា។ ការធ្វើពិសោធលើមុខវិជ្ជាវិទ្យាសាស្ត្រ ពិតជាមានអត្ថប្រយោជន៍យ៉ាងច្រើន ចំពោះការបង្រៀន និងរៀន ដែលជួយឱ្យសិស្សចេះអភិវឌ្ឍខ្លួនឯង មានជំនាញកំណត់ទិសដៅ ចេះរៀបចំផែនការ និងដោះស្រាយបញ្ហា ជំរុញការអភិវឌ្ឍគំនិតបញ្ញា មានជំនឿទុកចិត្តលើចំណេះដែលទទួលបានពីការពិសោធ បង្កើតនូវគំនិតច្នៃប្រឌិតថ្មី បណ្ដុះបំណិនវិជ្ជាជីវៈ ចេះអំពីរបៀបសួរសំណួរ គិតស៊ីជម្រៅ ស្រាវជ្រាវ សង្កេត វិភាគ និងយល់ដឹងអំពីពិភពលោកកាន់តែប្រសើរ។

វិទ្យាស្ថានជាតិអប់រំ បានរៀបចំចងក្រងសៀវភៅពិសោធ សម្រាប់ការបណ្ដុះបណ្ដាលគ្រូបង្រៀនមធ្យមសិក្សាទុតិយភូមិផ្នែកវិទ្យាសាស្ត្រ ដែលខ្លឹមសារសៀវភៅរួមមាន ការរៀបចំសន្លឹកកិច្ចការពិសោធ សម្ភារៈពិសោធ វិធីសាស្ត្របង្រៀនពិសោធ និងការធ្វើពិសោធជាក់ស្ដែង។

ក្រសួងអប់រំ យុវជន និងកីឡា សង្ឃឹមទុកថា ឯកសារនេះ នឹងបានជាប្រយោជន៍ដ៏សំខាន់ សម្រាប់អ្នកអនុវត្ត ជាពិសេសគ្រូបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិដែលទទួលបានការបណ្ដុះបណ្ដាលពីវិទ្យាស្ថានជាតិអប់រំ ក្នុងការអនុវត្តពិសោធ ប្រកបដោយគុណភាព ប្រសិទ្ធភាពខ្ពស់ និងជំរុញការអប់រំវិទ្យាសាស្ត្រនៅកម្ពុជាឱ្យមានការអភិវឌ្ឍដូចបណ្ដាប្រទេសនានាក្នុងតំបន់ និងលើសកលលោក។

ថ្ងៃព្រហស្បតិ៍ ៤កើត ខែចេត្រ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែមេសា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

# អារម្ភកថា

ការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស ដើម្បីឱ្យមានគុណភាព ទាំងផ្នែកវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា។

ឯកសារបំប៉នផ្នែកពិសោធន៍ផែនដីនិងបរិស្ថានវិទ្យានេះត្រូវបានរៀបចំឡើងដើម្បីប្រើប្រាស់ក្នុងគោលបំណងលើកកម្ពស់សមត្ថភាពគ្រូ និងជំនួយស្មារតីក្នុងការបង្ហាត់បង្រៀនសិស្ស ស្របតាមកម្មវិធីសិក្សានិងសៀវភៅសិក្សានៅតាមសាលាចំណោះទូទៅ ជាពិសេសនៅក្នុងកម្រិតវិទ្យាល័យ។

ខ្លឹមសារនៅក្នុងសៀវភៅនេះ ចែកចេញជា បីផ្នែក រួមមាន(១) **ការផលិតសម្ភារឧបទេស** គឺសំដៅលើការច្នៃសម្ភារឧបទេសងាយៗ របៀបប្រើប្រាស់សម្ភារពិសោធន៍ (២) **ការសរសេរសន្លឹកកិច្ចការពិសោធន៍** សំដៅលើការអនុវត្តវិធីសាស្ត្របង្រៀនមានដូចជាការបង្រៀននិងរៀនតាមបែបរិះរក ការប្រើវិធីវិទ្យាសាស្ត្រ ឬយុទ្ធវិធីផ្សេងៗជាដើម និង(៣) **សារៈប្រយោជន៍នៃសម្ភារឧបទេស** ជាចំណែកមួយក្នុងការពង្រីកចំណេះដឹងរបស់គ្រូដែលធ្វើឱ្យការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាពថែមទៀត។

យើងខ្ញុំសង្ឃឹមថា សៀវភៅនេះនឹងផ្តល់សារៈប្រយោជន៍យ៉ាងច្រើនដល់លោកគ្រូ អ្នកគ្រូបង្រៀនផ្នែកផែនដីនិងបរិស្ថានវិទ្យាសម្រាប់ជួយសម្រួលក្នុងការបង្រៀនទ្រឹស្តីនិងធ្វើពិសោធដោយប្រើប្រាស់សន្លឹកកិច្ចការពិសោធន៍។ វាក៏ជួយជំរុញ និងលើកទឹកចិត្តក្នុងការបង្រៀន និងរៀនដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល ដើម្បីឱ្យការបង្រៀន និងរៀនសិស្សានុសិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់។

យើងខ្ញុំជឿជាក់ថា ឯកសារនេះពិតជានៅមានចំណុចខ្វះចន្លោះ ដោយចៀសមិនផុតនោះឡើយ។ យើងខ្ញុំសង្ឃឹមថា លោកគ្រូ អ្នកគ្រូនឹងជួយផ្តល់ជាមតិយោបល់បំពេញបន្ថែមក្នុងន័យស្ថាបនា ដើម្បីកែលម្អឯកសារនេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរ និងមានប្រសិទ្ធភាពថែមទៀត។

## ១. គណៈកម្មការគ្រប់គ្រង

១. ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

២. ឯកឧត្តមបណ្ឌិតសភាចារ្យ **ណាត ប៊ុនរឿន** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា

៣. ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកនៃវិទ្យាស្ថានជាតិអប់រំ

៤. លោក **ថៃ ហេង** នាយករងនៃវិទ្យាស្ថានជាតិអប់រំ

## ២. គណៈកម្មការនិពន្ធ រៀបរៀង និងចងក្រងសៀវភៅ

១. លោក **នី សុពុទ្ធី** គ្រូឧទ្ទេសផែនដី និងបរិស្ថានវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

២. លោក **ម៉ែន ចំរើន** គ្រូឧទ្ទេសផែនដី និងបរិស្ថានវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

៣. លោក **កែវ រីណា** គ្រូឧទ្ទេសផែនដី និងបរិស្ថានវិទ្យានៃវិទ្យាស្ថានជាតិអប់រំ

## ៣. គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

១. លោក **ម៉ៅ សារឿន** ប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

២. លោក **ចេង ថុន** អនុប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

៣. លោក **គឹម លាង** អនុប្រធានដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ

# មាតិកា


បុព្វកថា ..... i
អារម្ភកថា ..... ii
សេចក្តីផ្តើម ..... 1
១. គោលបំណង ..... 1
២. និយមន័យ ..... 1
៣. ប្រភព ..... 2
៤. ការផលិតសម្ភារឧបទេស និងប្រើប្រាស់សម្ភារឧបទេស ..... 2
៥. ការសរសេរសន្លឹកកិច្ចការពិសោធន៍ ..... 12
៥.១ .ប្រធានបទទី១៖ កំណើនកម្តៅលើពិភពលោក ..... 12
៥.២ ប្រធានបទទី២ ៖ ការបំពុល ឬ កង្វក់ ..... 17
៦. វិធីសាស្ត្របង្រៀន និងរៀនពិសោធន៍ ..... 23
៧. សារៈប្រយោជន៍នៃសម្ភារឧបទស ..... 23
ឯកសារយោង ..... 24

# សេចក្តីផ្តើម

នៅក្នុងប្រព័ន្ធអប់រំ ទន្ទឹមនឹងមានអាគារសិក្សាល្អហើយនោះមិនទាន់គ្រប់គ្រាន់ដើម្បីធ្វើដំណើរឆ្ពោះទៅរកការអប់រំដ៏ប្រសើរនោះទេ ចាំបាច់ណាស់ត្រូវតែមានការបង្រៀនមួយ ប្រកបដោយប្រសិទ្ធភាព។ជាតុសំខាន់ៗនៃការបង្រៀនគឺគ្រូបង្រៀនសិស្សានុសិស្ស ថ្នាក់រៀនកម្មវិធីសិក្សាសម្ភារឧបទេសនិងរដ្ឋបាលសិក្សា។ ប្រសិនបមានកម្មវិធីសិក្សា( curriculum )ល្អហើយ ប៉ុន្តែគ្រូបង្រៀនខ្វះខាត ឬគ្មានវិធីសាស្ត្រក្នុងការផ្ទេរចំណេះដឹងទៅសិស្សានុសិស្ស នោះដំណើរការបង្រៀន ឬប្រព័ន្ធអប់រំនោះមិនអាចឆ្ពោះទៅរកការអប់រំដ៏មានប្រសិទ្ធភាពបានឡើយ។

ការបង្រៀន ជាមាគ៌ាក្នុងការផ្តល់ចំណេះដឹងដល់សិស្សានុសិស្ស តាមរយៈការបប្រើប្រាស់វិធីសាស្ត្រ និងយុទ្ធវិធីនានាដើម្បីឱ្យសិស្សានុសិស្សមានការអភិវឌ្ឍផ្នែកបញ្ញាស្មារតី និងរាងកាយ។

វិធីសាស្ត្របង្រៀន គឺជាយុទ្ធវិធី ឬមធ្យោបាយមួយធ្វើឱ្យការងាររបស់គ្រូបង្រៀន ផ្តល់ដល់សិស្សានុសិស្សទទួលបាននូវចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់ ចេះរស់នៅជាមួយគ្នា ព្រមទាំងពង្រីកសតិ និងបញ្ញាស្មារតី។

គោលវិធីនៃការបង្រៀនត្រូវទទួលស្គាល់ជាទូទៅថាមានពីរធំៗគឺគោលវិធីគ្រូមជ្ឈមណ្ឌល និងគោលវិធីសិស្សមជ្ឈមណ្ឌល។

គោលវិធីសិស្សមជ្ឈមណ្ឌលមាន វិធីបែបសហការវិធីពិភាក្សា វិធីបង្រៀននិងរៀនតាមបែបរិះរក វិធីវិទ្យាសាស្ត្រ...ជាដើម។

## ១. គោលបំណង

- បង្ហាញពីរបៀបសរសេរសន្លឹកកិច្ចការពិសោធន៍
- កំណត់បានពីប្រភពនៃសម្ភារឧបទេស
- រៀបរាប់បានពីរបៀបប្រើប្រាស់សម្ភារពិសោធន៍
- កែច្នៃសម្ភារឧបទេសងាយៗ ដើម្បីជាជំនួយក្នុងការបង្រៀនពិសោធន៍
- ជ្រើសរើសវិធីសាស្ត្រក្នុងការបង្រៀនពិសោធន៍
- រៀបរាប់បានពីសារៈប្រយោជន៍នៃការប្រើប្រាស់សម្ភារឧបទេស
- ជំរុញ និងលើកទឹកចិត្តគ្រូបង្រៀនឱ្យបង្រៀនដោយប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌល

## ២. និយមន័យ

សម្ភារឧបទេស ជាឧបករណ៍ ឬសម្ភារជាក់ស្តែង ដែលគ្រូត្រូវប្រើប្រាស់សម្រាប់ការបង្រៀននិងរៀនដើម្បីឱ្យខ្លឹមសារមេរៀនកាន់តែច្បាស់លាស់ ហើយងាយយល់។

វាអាចជាសម្ភារងាយរកបានសម្ភារច្នៃប្រឌិតដូចជា សៀវភៅសិស្ស សៀវភៅគ្រូ រូបភាព រូបថត ប័ណ្ណសំណួរ ឧបករណ៍ពិសោធន៍ សន្លឹកកិច្ចការ...សម្ភារចាំបាច់ដទៃទៀតសមស្របតាមមេរៀន។

**វិធីសាស្ត្របង្រៀនតាមបែបរិះរក** តម្រូវឱ្យសិស្សានុសិស្សសង្កេត និងវិភាគអំពីបាតុភូតវិទ្យាសាស្ត្រ ដើម្បីបង្កើតសំណួរ ធ្វើពិសោធ ឬធ្វើការស្រាវជ្រាវ ដើម្បីឆ្លើយតបទៅនឹងសំណួររបស់ពួកគេ និងទាញសេចក្តីសន្និដ្ឋានសមស្របមួយតាមរយៈលទ្ធផលការធ្វើពិសោធ ឬការសិក្សាស្រាវជ្រាវ។ នៅក្នុងដំណើរការនេះ សិស្សានុសិស្សនឹងយល់ពីខ្លឹមសារមេរៀនបានស៊ីជម្រៅ ទទួលបានជំនាញ និងចំណេះដឹងបែបវិទ្យាសាស្ត្រយ៉ាងពិតប្រាកដ។

**វិធីវិទ្យាសាស្ត្រ** គឺ ជាវិទ្យាសាស្ត្រដែលជាការសិក្សាស្វែងយល់អំពីបាតុភូត ហេតុការណ៍ ឬព្រឹត្តិការណ៍ផ្សេងៗដែលកើតមានឡើងជុំវិញខ្លួនយើង ថាហេតុអ្វី បានជាមានបាតុភូតនោះកើតឡើង ហើយព្យាយាមពន្យល់

អំពីបាតុភូតនោះ ដើម្បីឱ្យគេបានដឹង និងបានយល់។ អ្នកដែលព្យាយាមពន្យល់ឱ្យគេបានយល់ពីបាតុភូតហេតុការណ៍ទាំងនោះត្រូវបានគេហៅថា " **អ្នកវិទ្យាសាស្រ្ត ឬអ្នកស្រាវជ្រាវវិទ្យាសាស្រ្ត** " ។ក្នុងការស្រាវជ្រាវអ្នកវិទ្យាសាស្រ្តបានប្រើវិធីរួមមួយ ហៅថា " **វិធីវិទ្យាសាស្រ្ត** " ។

**៣. ប្រភព**

សម្ភារឧបទេស ជាតម្រូវការចាំបាច់មួយសម្រាប់ការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធភាព។ ប្រភពនៃសម្ភារឧបទេស៖

- អាចរកបាននៅក្នុងបណ្ណាល័យ (ឯកសារពាក់ព័ន្ធ)
- មាននៅក្នុងមន្ទីរពិសោធន៍ (ចំពោះវិទ្យាសាស្រ្ត)
- អាចច្នៃប្រឌិតបានដោយងាយ និងមានតម្លៃសមស្រប
- ទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ
- មិនមានគ្រោះថ្នាក់ដល់មនុស្ស

**៤. ការផលិតសម្ភារឧបទេស និងប្រើប្រាស់សម្ភារឧបទេស**

ក. តារាងបញ្ជីឈ្មោះសម្ភារឧបទេស

| ល.រ | ឈ្មោះសម្ភារឧបទេស | បរិមាណ | លក្ខណៈសម្គាល់ | ផ្សេងៗ |
|---|---|---|---|---|
| **មុខវិជ្ជា ៖ ផែនដី និងបរិស្ថានវិទ្យា** | | | | |
| 1 | គំរូ សិលា និងរ៉ែ<br>Minerals & Rocks sample<br>Collection of 49 different kind of mineral & rock. | 3 | EA | |
| 2 | ឧបករណ៍វាស់ដំណើរព្រះអាទិត្យ<br>Helios Planetarium | 1 | Set | |
| 3 | - ឧបករណ៍វាស់សំណើមដី (Sol Moisture Meter)<br>- ឧបករណ៍វាស់ពន្លឺ (Light Meter, Color LED)<br>- ឧបករណ៍វាស់សម្ពាធ សំណើម និងសីតុណ្ហភាព (Pressure/Humidity/Temp Datalogger) | 3 | Set | |
| 4 | បន្ទះប៉ូឡារ៉ាយ (Polarizing Film Sheet)<br>Polarizing Film Sheet-Set of 10 | 3 | Set | |
| 5 | កែវយឹតមើលពេលរាត្រី (Binocular (night time vision)) | 2 | EA | |
| 6 | កែវយឹតមើលពេលថ្ងៃ (Binocular (day time vision) | 2 | EA | |
| 7 | ផ្ទាំងរូបភាពវដ្តទឹក (Water Cycle Poster) | 2 | Unit | |
| 8 | ផ្ទាំងរូបភាពតំបន់ឆ្នេរ (Coasts Poster) | 2 | Unit | |

| | | | | |
|---|---|---|---|---|
| 9 | រូបផែនទីធរណីលើពិភពលោក ( Poster-Map: Geological Map of the world ) | 2 | Unit | |
| 10 | ផ្ទាំងរូបភាពការវិវត្ត ( Evolution Poster ) | 2 | EA | |
| 11 | ផែនទីនយោបាយ ( Political World Map ) | 2 | Set | |
| 12 | ផ្ទាំងរូបភាពការកើនកម្តៅផែនដី ( Global Warming Poster ) | 2 | EA | |
| 13 | ផែនទីល្វែងម៉ោងលើផែនដី ( World Time Zone Map ) | 2 | EA | |
| 14 | ផ្ទាំងរូបភាពការកែច្នៃ ( Recycle Poster ) | 2 | EA | |
| 15 | ផែនទីពិភពលោក ( School World Atlas ) | 2 | Notes | |
| 16 | គ្លីណូម៉ែត្រ ( Clinometer ) | 3 | EA | |
| 17 | ផ្ទាំងរូបភាពអំពីលំហ ( Space Posters in English Pack of 4 pcs ) | 2 | Pack | |
| 18 | ដុំមផ្លាស្ទិចថ្លា ( Plastics Geometric Solids, Transparent, 8 Pcs ) | 2 | Set | |
| 19 | Sieve Test Set | 2 | Set | |
| 20 | ភូគោល ( Earth Global, dia 32 cm ) | 2 | EA | |
| 21 | គំរូទម្រង់ក្នុងផែនដី ( Model of Earth Internal Structure Demonstration with Magnetic) | 2 | EA | |
| 22 | ស្វ៊ែរមេឃថ្លា ( Transparent Celestial Global, dia 32 cm ) | 2 | EA | |
| 23 | គំរូរយៈទទឹង និងរយៈបណ្តោយ ( Longitudinal and Latitudinal Model, dia 32 cm ) | 2 | EA | |
| 24 | គំរូស្វ៊ែរមេឃប្រើពន្លឺ | 2 | EA | |
| 25 | គំរូព្រះអាទិត្យ ផែនដី និងព្រះចន្ទ ( Sun-Earth-Moon Model ) | 2 | EA | |
| 26 | គំរូប្រព័ន្ធព្រះអាទិត្យ ( Solar System Model ) | 2 | EA | |
| 27 | គំរូព្រះអាទិត្យ ( The Model of the Sun, dia 32 cm ) | 2 | EA | |
| 28 | គំរូឧបករណ៍វាស់រញ្ជួយដី ( Seismograph Model ) | 2 | EA | |

| | | | | |
|---|---|---|---|---|
| 29 | ឧបករណ៍វាស់ដំណើរព្រះអាទិត្យ ( Sunshine Recording ) | 2 | EA | |
| 30 | ឧបករណ៍វាស់រយៈកម្ពស់ព្រះអាទិត្យ ( Sun Height Tester ) | 2 | EA | |
| 31 | ញញួរវាយថ្ម ( Geology Hammer, approx.850g ) | 5 | EA | |
| 32 | ភ្លៀងម៉ែត្រ ( Rain Gauge ) | 5 | EA | |
| 33 | ឧបករណ៍វាស់ល្បឿនខ្យល់ ( Vane Anemometer ) | 5 | EA | |
| 34 | គំរូបំណាក់ស្រុត ( Model of the makeup of fault age zone and cultivation of rift valleys ) | 2 | EA | |
| 35 | គំរូបំណាក់ស្រុត ( Fault board model ) | 2 | EA | |
| 36 | គំរូភ្នំភ្លើង ( Model Of Volcanoes ) | 2 | EA | |
| 37 | ស្ថានីយ៍ធាតុអាកាស ( Weather Station ) | 2 | Set | |
| 38 | មីក្រូទស្សន៍សង្កេតសិលា ( Trinocular Polarizing Microscope )<br>**Accessories included:**<br>- Lamp house adjustment objective<br>- Mechanical stage, Moving rang 30*40mm<br>- Specimen presser<br>- Micrometer | 1 | Set | |
| 39 | Digital Camera, 5 MP.COMS | 1 | EA | |
| 40 | គំរូផូស៊ីល ( Fossil Sets ):<br>An ideal advanced fossil collection set for A level college. University courses or individual use. The set is comprised of 36 high quality genuine fossil specimens selected from the main fossil group. The box measures 37*37*5 cm deep & comes with a*100 quality hand lens. | 1 | | |
| 41 | ឧបករណ៍វាស់គុណភាពទឹក ( Water Quality Test Kit )<br>4-in-1 Chlorine, pH ORP and Temperature Kit | 1 | Kit | |
| 42 | ឧបករណ៍វាស់គុណភាពខ្យល់ ( Ari Quality Meter )<br>$Co_2$: 0 to 4,000 ppm<br>Datalogging: 20 M data using 2 GSD memory card | 2 | Unit | |
| 43 | - ឧបករណ៍វាស់សំណើមដី ( Sol Moisture Meter )<br>- ឧបករណ៍វាស់ពន្លឺ ( Light Meter, Color LED )<br>- ឧបករណ៍វាស់សម្ពាធ សំណើម និងសីតុណ្ហភាព ( Pressure/Humidity/Temp Datalogger ) | 2 | Set | |

| | | | | |
|---|---|---|---|---|
| 44 | GPS ( Handheld GPS Navigator, Garmin e Terex 30%) | 2 | Set | |
| 45 | ដីឥដ្ឋគំរូ ( Clay, 7 Colors | 3 | Set | |

## ខ. ការប្រើប្រាស់សម្ភារ

### ១. កែវបេស៊ែ

**ប្រភេទ** កែវបេស៊ែ អាចជាកែវ ឬជាជ័រថ្លាដែលមានទំហំផ្សេងៗគ្នាដូចជា 10mL, 25mL,100mL 250mL, 500mL, 1000mL...។ កែវបេស៊ែដែលផលិតចេញពីកែវមាន ពីរប្រភេទទៀតគឺ កែវ PYREX និងមិនមែនជាPYREX។

យើងអាចដឹងពីប្រភេទកែវទាំងនោះ ដោយពិនិត្យមើលអក្សរដែលគេសរសេរលើសំបកកែវស្រាប់ កែវប្រភេទ PYREX មានលក្ខណៈធន់នឹងកម្តៅ ជាងកែវមិនមែនជាប្រភេទ PYREX តែជាអាចប្រើវាបានដូចគ្នា។



**របៀបប្រើប្រាស់** ដុតកម្តៅអង្គធាតុរាវផ្សេងៗឱ្យពុះ។ ផ្ទុកសារធាតុគីមីផ្សេងៗក្នុងរយៈពេលខ្លី។ រំលាយ និងធ្វើសូលុយស្យុងផ្សេងៗ ផ្ទេរសូលុយស្យុង ឬសារធាតុគីមី។

### ២. បំពង់សាក

**ប្រភេទ** បំពង់សាកអាចមានទំហំតូចធំ និងមានប្រភេទ PYREX និងមិនមែន PYREX ដែលគេអាចមើលឃើញនៅលើបំពង់សាក។ បំពង់សាកខ្លះមានក្រិតមាឌនៅលើនោះ តែបំពង់សាកភាគច្រើនពុំមានក្រិតទេ។



**របៀបប្រើប្រាស់** បំពង់សាកអាចត្រូវបានប្រើសម្រាប់ដុតកម្តៅអង្គធាតុរឹងផ្សេងៗដោយផ្ទាល់នឹងអណ្តាតភ្លើងក្នុងប្រតិកម្មបំបែកដោយកម្តៅ។ ដុតកម្តៅអង្គធាតុរាវ។ តេស្តមើលពីប្រតិកម្មផ្សេងៗ ដូចជា ការប្តូរពណ៌ ការបង្កើតកករ និងការបង្កើតឧស្ម័នជាដើម។ ត្រងយកឧស្ម័នដែលភាយចេញពីប្រតិកម្មផ្សេងៗ ដូចជាក្នុងអគ្គិសនីវិភាគ។

### ៣. ទែម៉ូម៉ែត្រ ឬ សីតុណ្ហមាត្រ

**ប្រភេទ** ទែម៉ូម៉ែត្រមានពីរប្រភេទគឺប្រភេទអាណាឡូក និងប្រភេទឌីជីថល។ទែម៉ូម៉ែត្រដែលគេប្រើញឹកញាប់ក្នុងមន្ទីរពិសោធ គឺប្រភេទអាណាឡូកដែលប្រភេទនេះអាចជាទែម៉ូម៉ែត្របារ៉ត(ពណ៌សដូចប្រាក់ និងទែម៉ូម៉ែត្រអាល់កុល (ពណ៌ក្រហម ឬខៀវ)។ ទែម៉ូម៉ែត្រឌីជីថលជាទូទៅ គេប្រើចរន្តអគ្គិសនីនិងមានអេឡិចត្រូតលោហៈដែលគេអាចវាស់សីតុណ្ហភាព ដោយសារអេឡិចត្រូតលោហៈនេះ និងអាចអានតម្លៃសីតុណ្ហភាពនៅលើអេក្រង់បាន។



**របៀបប្រើប្រាស់** គេអាចប្រើទែម៉ូម៉ែត្រវាស់សីតុណ្ហភាពផ្សេងៗ ដូចជា សីតុណ្ហភាពរលាយ សីតុណ្ហភាពរំពុះនៃសារធាតុគីមីជាដើមដោយដាក់វាចូលទៅក្នុងតំបន់ ឬសារធាតុដែលចង់វាស់

សីតុណ្ហភាព និងអានតម្លៃតាមរយៈក្រិត ឬអេក្រង់បាន
បង្ហាញនោះ។

<u>**៤. ស៊ីឡាំងក្រិត**</u>

**ប្រភេទ** ស៊ីឡាំងក្រិតមានជាប្រភេទកែវ និងប្រភេទជ័រ។ វាអាចមានទំហំតូច ធំដូចជា
ចំណុះ10mL, 50mL, 100mL, 500mL, 1000mL។



**របៀបប្រើប្រាស់** មុខងារសំខាន់នៃការប្រើប្រាស់ស៊ីឡាំងក្រិតគឺ
ដើម្បីវាស់មាឌរបស់វត្ថុនានា អាចជាអង្គធាតុរាវ រឹង និងឧស្ម័ន។
ក្រៅពីនេះគេក៏អាចប្រើស៊ីឡាំងក្រិតសម្រាប់ពង្រាវសូលុយស្យុង
ជំនួសកែវវាស់មាឌផងដែរ។

<u>**៥. ដបលាង**</u>

**ប្រភេទ** ជាប្រភេទដបជ័រដែលមានទុយោរឹងភ្ជាប់ទៅនឹងគម្រប
សម្រាប់បាញ់ទឹកលាងឧបករណ៍ផ្សេងៗ និងសម្រាប់ផ្ទុកទឹកបិត។



**របៀបប្រើប្រាស់** ជាទូទៅដបនេះសម្រាប់ដាក់ទឹកបិត ឬទឹក
បណ្តូរអ៊ីយ៉ុង ឬទឹកស្អាតសម្រាប់បាញ់លាងជម្រះឧបករណ៍
ពិសោធន៍នៅវគ្គចុងក្រោយ បន្ទាប់ពីលាងជាមួយទឹកសាប៊ូ
និងទឹកម៉ាស៊ីនរួច។

<u>**៦. ក្រដាសតួណឺសុល**</u>

**ប្រភេទ** ក្រដាសតួណឺសុលមានពីរប្រភេទ គឺក្រដាសតួណឺសុល
ខៀវនិងក្រដាសតួណឺសុលក្រហម។



**របៀបប្រើប្រាស់** ក្រដាសតួណឺសុលត្រូវបានគេប្រើ ដើម្បីធ្វើ
តេស្តលក្ខណៈអាស៊ីត-បាសនៃសូលុយស្យុង។

<u>**៧. ក្រដាស PH**</u>

**ប្រភេទ** ក្រដាស PHមិនមានច្រើនប្រភេទទេបើទោះជាខ្លះគេធ្វើវាជា
ក្រដាសតូចៗឬជាដុំរមូលដោយក៏វានៅតែជាប្រភេទដូចគ្នាដដែល។



**របៀបប្រើប្រាស់** ក្រដាស PH ត្រូវបានគេប្រើដូចក្រដាសតួណឺសុល
ដែរ តែវាមានក្ខណៈប្រសើរជាង។ ដើម្បីវាស់ pH នៃសូលុយស្យុង
គេយកក្រដាស PH ជ្រលក់ក្នុងសូលុយស្យុងនោះ រួចលើកមកវិញ
ហើយទុកវាឱ្យស្ងួត ទើបយកវាទៅប្រៀបធៀបពណ៌ស្តង់ដារបស់វា
និងអានតម្លៃ PH ទៅតាមនោះ។

<u>**៨. ជញ្ជីងអេឡិចត្រូនិក**</u>

**ប្រភេទ** ជញ្ជីងអេឡិចត្រូនិក ជាជញ្ជីងដើរដោយថាមពលអគ្គិសនី។ ជញ្ជីងខ្លះអាចប្រើថ្មពិលក៏បាន
ជញ្ជីងនេះអាចមានសមត្ថភាពថ្លឹងបានសុក្រិតខ្លាំង រហូតដល់គេអាចទទួលបានតម្លៃលេខ៤ខ្ទង់
ក្រោយក្បៀសទៅតាមប្រភេទដែលគេផលិត។

**របៀបប្រើប្រាស់** របៀបប្រើប្រាស់ជញ្ជីងអេឡិចត្រូនិក

1. ចុចកុងតាក់ភ្ជាប់ចរន្តអគ្គិសនី។
2. ដាក់ក្រដាសទ្រាប់សារធាតុគីមី ឬឧបករណ៍ផ្សេងទៀត ដូចជាកែវបេស៊ែ ឬកែវអែកឡែនជាដើម។
3. ចុចប៊ូតុងដែលមានសរសេរអក្សរថា “TARE” ឬ “Zero”ដើម្បីផាត់សំបក និងឱ្យជញ្ជីងបង្ហាញលេខសូន្យ។
4. ដាក់សារធាតុគីមីចូល ដើម្បីថ្លឹងនៅចំនួនដែលយើងត្រូវការ។
5. បិតកុងតាក់អគ្គិសនីវិញក្រោយពីប្រើប្រាស់រួច។



## ៩. ក្រូណូម៉ែត្រ



**ប្រភេទ** ក្រូណូម៉ែត្រជាប្រភេទនាឡិកាឌីជីថល ដែលគេប្រើជានាឡិកាសម្រាប់ប្រើមើលម៉ោង និងសម្រាប់វាស់ពេលវេលាផង។

**របៀបប្រើប្រាស់** ក្រូណូម៉ែត្រត្រូវបានគេប្រើប្រាស់ជាទូទៅសម្រាប់វាស់រយៈពេលផ្សេងៗ ទាំងការសិក្សាវិទ្យាសាស្ត្រ និងផ្នែកកីឡា។ វាមានប៊ូតុងចំនួន៣គឺ MOOD សម្រាប់ចុចផ្លាស់ប្តូរពីការបង្ហាញម៉ោង ទៅជាក្រូណូម៉ែត្រសម្រាប់វាស់រយៈពេល។ START/STOPសម្រាប់ចុចពេលចាប់ផ្តើមវាស់រយៈពេលនិងចុចម្តងទៀតនៅពេលវាស់បានបញ្ចប់។ រយៈពេលដែលវាស់បាននោះនឹងបង្ហាញ នៅលើអក្សររបស់ក្រូណូម៉ែត្រ។ RESET សម្រាប់ចុចឱ្យលេខប្តូរទោជា 0:00:00 វិញ ដើម្បីវាស់រយៈពេលផ្សេងទៀត។

## ១០. គំរូសិលា និងរ៉ែ




**ប្រភេទ** គំរូសិលា និងរ៉ែមានចំនួន ៤៩ប្រភេទខុសៗគ្នាដែលបានមកពីក្នុងសំបកផែនដី។

**របៀបប្រើប្រាស់** ជាទូទៅគេប្រើប្រាស់គំរូសិលា និងរ៉ែតាមរយៈពេលការសង្កេតផ្ទាល់ ដោយប្រើប្រាស់ភ្នែកទទេ ឬប្រើកែវពង្រីក។ អ្នកសិក្សាអាចសង្កេតទៅលើវាយភាពខាងក្រៅដូចជាពណ៌ ទំហំក្រាម ភាពភ្លឺ ឬអាចពិនិត្យទៅលើសារធាតុគីមីសាមញ្ញមួយចំនួន ទៅតាមប្រភេទ ឬក្រុមនៃរ៉ែ និងសិលា។

## ១១. គំរូប្រព័ន្ធព្រះអាទិត្យ

**ប្រភេទ** ប្រភេទគំរូប្រព័ន្ធព្រះអាទិត្យមាន ដូចជាប្រើថ្ម ប្រើអគ្គិសនីនិងគ្មានចលនា។ ប្រភេទដែលបង្ហាញនេះពុំមានចលនាទេ គឺគ្រូត្រូវប្រើដៃបង្វិលបង្ហាញដោយផ្ទាល់ទៅសិស្ស។



**របៀបប្រើប្រាស់** គ្រូប្រើគំរូនេះដើម្បីកំណត់ទីតាំង និងបង្ហាញចលនារបស់ភពទាំងប្រាំបីក្នុងប្រព័ន្ធព្រះអាទិត្យ។ សិស្សក៏អាចរៀបរាប់បានពីរូបរាងខាងក្រៅរបស់អង្គនីមួយៗបានផងដែរ។

១២.ឧបករណ៍វាស់សំណើមដី ពន្លឺ និងសំណើមអាកាស



**ប្រភេទ** ឧបករណ៍នេះមានមុខងារ បីយ៉ាង គឺសម្រាប់វាស់សំណើមដី សំណើមបរិយាកាស និងកម្រិត ពន្លឺព្រះអាទិត្យ។ ឧបករណ៍នេះមានច្រើនសណ្ឋានសម្រាប់ប្រើប្រាស់ ជាប្រភេទឌីជីថល ប្រភេទប្រើថ្មពិល និងមិនមានថ្មពិល។

**របៀបប្រើប្រាស់** ជាដំបូងគេត្រូវដោតចុងដែក Sensor ចូលទៅក្នុងដី

ថ្នមៗកុំឱ្យបាក់។ បន្ទាប់គេអានកម្រិតសំណើមដី សំណើមអាកាស និងកម្រិតពន្លឺព្រះអាទិត្យតាមរយៈទ្រនិចដែលចង្អុលប្រាប់ ជាកម្រិតទាប មធ្យម ឬខ្ពស់។

១៣. បន្ទះប៉ូឡារ៉ាយ



**ប្រភេទ** បន្ទះប៉ូឡារាយនេះមានតែមួយប្រភេទទេ ប៉ុន្តែមានច្រើនខ្នាត ឬទំហំ។

**របៀបប្រើប្រាស់** ជាទូទៅគេប្រើបន្ទះនេះសម្រាប់សង្កេតក្រាមសិលា ឬរ៉ែតាមរយៈមីក្រូទស្សន៍។ ជាធម្មតាគេប្រើវាពីរបន្ទះជាមួយគ្នាដាក់នៅលើបន្ទះសង្កេតនៃមីក្រូទស្សន៍។ លក្ខណៈរបស់បន្ទះនេះ គឺបិទ និងបើកពន្លឺដើម្បីសង្កេតសិលា ឬរ៉ែ។ នៅពេលគេគងបន្ទះនេះឱ្យបិទពន្លឺ ពេលនោះគេអាចសង្កតឃើញពណ៌របស់ក្រាមសិលា ឬរ៉ែដោយងាយស្រួលក្នុងការសង្កេត។

១៤. គ្លីណូម៉ែត្រ

**ប្រភេទ** គ្លីណូម៉ែត្រអាចមានជាប្រភេទអាណាឡូក ឬប្រភេទឌីជីថល។ ប្រភេទដែលបង្ហាញនេះ គឺ ជា ប្រភេទអាណាឡូក។ គ្លីណូម៉ែត្រដែលបង្ហាញនេះ គឺមានភ្ជាប់ជាមួយនូវត្រីវិស័យសម្រាប់សម្គាល់ទិសផងដែរ។



**របៀបប្រើប្រាស់** ជាទូទៅ គេប្រើគ្លីណូម៉ែត្រដើម្បីវាស់រយៈកម្ពស់អង្គនៅលើមេឃ មុំជម្រាលនៃផ្ទៃដី និងមុំជម្រាលរបស់ស្រទាប់សិលា។ ដំបូងគេត្រូវបើកគម្របរបស់ឧបករណ៍ ហើយដាក់ផ្ទាំងទ្រនិចមុំ និងកញ្ចក់គោលដៅឱ្យត្រង់។ បន្ទាប់មក គេកាន់ឧបករណ៍ដាក់ក្បែរភ្នែក ដើម្បីសង្កេតវត្ថុលើមេឃ ឬដាក់ផ្ទាល់នៅលើស្រទាប់សិលា។

១៥. ភ្លៀងម៉ែត



**ប្រភេទ** ភ្លៀងម៉ែត្រអាចមានប្រភេទវាស់ដោយស្វ័យប្រវត្តិ និងមិនស្វ័យប្រវត្តិវាស់ដោយមនុស្សផ្ទាល់។ ប្រភេទស្វ័យប្រវត្តិអាចភ្ជាប់ជាមួយកុំព្យូទ័រ ចំណែកប្រភេទធម្មតាដូចមានបង្ហាញនេះត្រូវការមនុស្សអានកម្ពស់ទឹកភ្លៀង និងកត់ត្រាទុក។

**របៀបប្រើប្រាស់** ជាទូទៅគេដាក់ ឬដោតភ្លៀងម៉ែត្រ នៅទីវាល

ខាងក្រៅអគារ។ ឧបករណ៍នេះងាយស្រួលប្រើ ដោយគ្រាន់តែ
អាន និងកត់ត្រាកម្ពស់ទឹកភ្លៀងនៅពេលមានកំណកអាកាស
កើតឡើង។

**១៦. ឧបករណ៍វាស់ល្បឿនខ្យល់បក់**



**ប្រភេទ** ឧបករណ៍វាស់ល្បឿនខ្យល់បក់អាចមានប្រភេទឌីជីថល និង អាណាឡូក។ ប្រភេទឌីជីថលអាចអានលេខដោយផ្ទាល់បាន ចំណែកប្រភេទអាណាឡូក ត្រូវការមេនុស្សគណនា។

**របៀបប្រើប្រាស់**:ជាទូទៅគេដាក់ឬដោតឧបករណ៍វាស់ល្បឿនខ្យល់បក់នៅទីវាលក្រៅអគារឧបករណ៍វាស់ល្បឿនខ្យល់បក់ប្រភេទឌីជីថលងាយស្រួលប្រើដោយគ្រាន់តែអាន និងកត់ត្រាល្បឿនខ្យល់នោះជាការស្រេច ។

**១៧. តេឡេទស្សន៍**

**ប្រភេទ** តេឡេទស្សន៍គឺជាឧបករណ៍សម្រាប់ទាញវត្ថុដែលនៅឆ្ងាយឱ្យមើលឃើញជិត។ តេឡេទស្សន៍អុបទិចប្រមូលពន្លឺដើម្បីឱ្យការសង្កេតកាន់តែជិត។តេឡេទស្សន៍មានពីរប្រភេទ គឺ តេឡេទស្សន៍ចំណាំងបែរ និងតេឡេទស្សន៍ចំណាំងផ្លាត។



តេឡេទស្សន៍ចំណាំងបែរ



តេឡេទស្សន៍ចំណាំងផ្លាត

**របៀបប្រើប្រាស់**៖ ដើម្បីប្រើប្រាស់តេឡេទស្សន៍ឱ្យបានត្រឹមត្រូវ ដំបូងគេត្រូវតម្រង់វាឱ្យត្រូវនឹងអ័ក្សរង្វិលខ្វាល់របស់ផែនដី។

ក. តំរង់ឧបករណ៍កំណត់រយៈបណ្ដោយមេឃ ឆ្ពោះទៅប៉ូលខាងជើង និងកំណត់រយៈទទឹង ទីតាំងកំពុងសង្កេត។

ខ. ថ្លឹងលំនឹងតេឡេទស្សន៍ដើម្បីឱ្យការសង្កេតបានល្អ។

គ. កំណត់ទិសដៅសង្កេត៖

១). ដើម្បីកំណត់រយៈទទឹងមេឃ គេប្រើរឹសកំណត់រយៈទទឹងមេឃ ឬរឹសតម្រូវរយៈទទឹងមេឃ

២). ដើម្បីកំណត់រយៈបណ្ដោយមេឃ គេប្រើរឹសកំណត់រយៈបណ្ដោយមេឃ ឬរឹសតម្រូវរយៈបណ្ដោយមេឃ។

ឃ. ការប្រើប្រាស់កែវឆ្លុះកំណត់ទីតាំង

កែវឆ្លុះកំណត់ទីតាំង គឺជាឧបករណ៍មួយដែលគេភ្ជាប់មកជាមួយនឹងតេឡេទស្សន៍សម្រាប់ជួយ យើងក្នុងការដៅទីតាំងវត្ថុនៅលើមេឃបានដោយងាយស្រួល និងរហ័ស។ កែវឆ្លុះនេះមានបន្ទាត់ ខ្វែង ដើម្បីជួយយើងកំណត់ទីតាំងវត្ថុ។ ប៉ុន្តែគេត្រូវដំឡើងវាជាមុនដូចខាងក្រោម៖

១). សង្កេតមើលតាមកែវឆ្លុះកំណត់ទីតាំង

២). តម្រង់វាទៅរកវត្ថុមួយ និងកំណត់ឱ្យអង្គនោះស្ថិតនៅចំកណ្ដាលនៅពេលប្រើកែវឆ្លុះដែលមានកម្រិតពង្រីកតូច។

៣). សង្កេតដោយបើកភ្នែកទាំងពីរទាល់តែឃើញអង្គនោះនៅក្នុងតេឡេទស្សន៍ចំកណ្ដាល។

ង. ប្រើប្រាស់កែកផ្តុះតាមកម្រិតពង្រីកដែលអ្នកចង់បាន និងប្រើវិសមួលឱ្យច្បាស់។

កម្រិតពង្រីក= ប្រវែងកំណុំរបស់តេឡេទស្សន៍ ៖ ប្រវែងកំណុំរបស់កែវផ្តុះ

កែវផ្តុះ 6.5 mm=800mm/6.5mm = 123x

កែវផ្តុះ 25 mm=800mm/25mm = 32x

ច. ការថែទាំ៖

_ ពេលឈប់ប្រើប្រាស់ ត្រូវរក្សាទុកកែវផ្តុះនៅក្នុងប្រអប់បិទជិតដើម្បីកុំឱ្យធូលីចូល។

_ប្រសិនបើមានធូលីចូល សូមប្រើខ្យល់បាញ់វាចេញ។

_ប្រសិនបើចង់សម្អាតកញ្ចក់ ឬកញ្ចក់ឡង់ទីមានបញ្ហា ត្រូវស្វែងរកអ្នកជំនាញឱ្យជួយ។

ដើម្បីសង្កេតអង្គក្នុងលំហ អ្នកគួរមានផែនទីតារា ឬផែនទីមេឃ។ គេអាចប្រើតេឡេទស្សន៍នេះ សម្រាប់សង្កេតអង្គខាងក្រោម៖

១). ព្រះចន្ទ គឺជាអង្គដែលសង្កេតបានល្អជាងគេ ហើយពេលវេលាដែលអាចសង្កេតបានល្អគឺនៅពេលព្រះចន្ទមិនពេញវង្ស ព្រោះពេលព្រះចន្ទពេញវង្សមានពន្លឺខ្លាំងពេក។

២). ភពចំនួន៥ គឺជាគោលដៅក្នុងការសង្កេត៖

_សង្កេតភពព្រហស្បតិ៍ជាមួយនឹងអ៊ិចក្រហម ពពករបស់ភព និងសង្កេតព្រះចន្ទរបស់វា

_សិក្សាពីភពសៅរ៍ និងកងវង្វង់របស់វា

_សង្កេតភពអង្គារ និងកន្ទ្បបទឹកកកនៅប៉ូល

_មើលភពពុធ និងភពសុក្រ

៣). មើលបម្រែបម្រួលស្នាមអ៊ុចនៅលើព្រះអាទិត្យ (ប្រសិនបើ មានតម្រងការពារពន្លឺព្រះអាទិត្យ)

៤). សង្កេតកម្រងតារា ណេប៊ុយឡា កាឡាក់ស៊ី តារាភ្លោះ ឬផ្កាយដុះកន្ទុយជាដើម។

## ១៨. មីក្រូទស្សន៍





**ប្រភេទ** ឧបករណ៍មួយប្រភេទដែលអ្នកវិទ្យាសាស្ត្រប្រើដើម្បីពង្រីកវត្ថុ ឬរូបធាតុដែលពុំអាចមើលឃើញ ដោយភ្នែកទទេ។ មីក្រូទស្សន៍មាន ២ប្រភេទ គឺមីក្រូទស្សន៍សមាស និងមីក្រូទស្សន៍អេឡិចត្រូនិក។ មីក្រូទស្សន៍សមាស ជាមីក្រូទស្សន៍ដែលប្រើបាច់ពន្លឺពីព្រះអាទិត្យ ឬអគ្គិសនី ដើម្បីចាំងចូលក្នុងកែវពង្រីក ចំណែកឯមីក្រូ ទស្សន៍អេឡិចត្រូនិក គឺជាមីក្រូទស្សន៍ដែលប្រើអេឡិចត្រុងដើម្បីពង្រីករូបភាព។

ផ្នែកផ្សេងៗ និងមុខងារនៃផ្នែកនីមួយៗរបស់មីក្រូទស្សន៍



| ល.រ | ផ្នែកផ្សេងៗនៃមីក្រូទស្សន៍ | មុខងារនៃផ្នែកនីមួយៗ |
|---|---|---|
| ១ | ដៃមីក្រូទស្សន៍ | សម្រាប់កាន់ និងទ្រទ្រង់បំពង់អូគុយលែ |
| ២ | អូគុយលែ(កែវពង្រីកភ្នែក) | មានកញ្ចក់ពង្រីកសម្រាប់ឆ្លុះមើលរូបភាពពិត |
| ៣ | បំពង់អូគុយលែ | កន្លែងភ្ជាប់អូគុយលែទៅ នឹងឈ្នាប់បង្វិល |
| ៤ | ឈ្នាប់បង្វិល | ទប់អុបសិចទីប និងបង្វិលអុបសិចទើបឱ្យចំទីតាំងដែលអាចមើលរូបភាពឃើញ និងបង្វិលប្តូរអុបសិចទើបតាមទំហំដែល ចង់ប្រើពីលេខតូចទៅលេខធំ |
| ៥ | អុបសិចទីប(កែវពង្រីកវត្ថុ) | កែវពង្រីកដែលមានលទ្ធភាពពង្រីករូបភាព ដែលមាន អនុភាពពង្រីកបាន 10x / 40x / 100x...... |
| ៦ | ដង្កៀប | សម្រាប់កៀបបន្ទះកញ្ចក់ឱ្យនៅជាប់លើថាស |
| ៧ | ថាស(ទ្របន្ទះឡាម) | ជាបន្ទះពណ៌ខ្មៅរាងបួនជ្រុង(ទ្រវែង)សម្រាប់ដាក់បន្ទះកញ្ចក់មើលភាគសំណាក |
| ៨ | ដ្យាប្រាម | សម្រាប់តម្រូវបរិវេណពន្លឺឱ្យចូលក្នុងបំពង់អូគុយលែ |
| ៩ | កញ្ចក់ទេរ | សម្រាប់ទាញស្រូបពន្លឺចូលក្នុងដ្យាប្រាម និងឆ្លងកាត់ទៅបន្ទះកញ្ចក់ និងកែវពង្រីកភ្នែក ឬអូគុយលែ |
| ១០ | ជើងទម្រ ឬបាត | សម្រាប់ទ្រមីក្រូទស្សន៍ |
| ១១ | វីសធំ | សម្រាប់មួលរំកិលបំពង់អូគុយលែឱ្យឡើងលើ ឬចុះក្រោម |
| ១២ | វីសតូច | សម្រាប់មួលតម្រូវគំហើញវត្ថុពិសោធ ឬភាគសំណាកឱ្យ ।កាន់តែច្បាស់ល្អ |

**របៀបប្រើប្រាស់** ជាទូទៅ យើងត្រូវរកកន្លែងដែលមានសភាពរាបស្មើ ដើម្បីដាក់មីក្រូទស្សន៍សម្រាប់មើលភាគសំណាកនានា និងមានការរៀបចំប្រើប្រាស់តាមដំណាក់កាលដូចខាងក្រោម៖

១. ពេលយកមីក្រូទស្សន៍ប្រើ ឬផ្លាស់ទីត្រូវតែយកដៃម្ខាងកាន់ដៃមីក្រូទស្សន៍ និងដៃម្ខាងទៀតទ្របាតមីក្រូទស្សន៍។

២. ដាក់មីក្រូទស្សន៍នៅកន្លែងដែលបានរៀបចំស្មើ ហើយគ្មានវត្ថុ ឬរបស់របរផ្សេងៗនៅក្បែរ។ ដាក់ដៃមីក្រូទស្សន៍ឆ្ពោះមករកខាងមុខអ្នកជានិច្ច។

៣. សម្លឹងមើលតាមបំពង់អូគុយលែ។ តម្រូវព្យាយាមដោយបិទ ឬបើកធ្វើឱ្យពន្លឺចូលឆ្លងកាត់ថាសបន្ទះឡាមបានច្បាស់ល្អ កុំខ្លាំងពេក និងងងឹតពេក។

៤. រៀបចំភាគសំណាកនៅលើបន្ទះឡាម បន្ទាប់មកគ្របឡាម៉ែលពីលើសំណាកដែលមាននៅលើបន្ទះឡាម ( គ្របថ្នមៗ យ៉ាងណាកុំឱ្យមានខ្យល់ចូល ដើម្បីឱ្យរូបភាពដែលពិនិត្យមើលឃើញកាន់តែច្បាស់ល្អ) រួចយកបន្ទះឡាមទៅដាក់លើថាសរបស់មីក្រូទស្សន៍ ហើយអាចប្រើដង្កៀប ដើម្បីកៀបបន្ទះឡាមនោះឱ្យនៅនឹង។

៥. ការចាប់ផ្តើមពិនិត្យដំបូង ត្រូវចាប់ផ្តើមប្រើអូគុយលែ និងអុបសិចទីប ពីលេខតូចសិន

៦. ដើម្បីឱ្យឆាប់ពិនិត្យឃើញរូបច្បាស់ល្អ បន្ទាប់ពីដាក់បន្ទះឡាមនៅលើថាស គឺចាំបាច់ត្រូវតែមួលវីសធំដើម្បីរំកិលអុបសិចទីបឱ្យអស់ដល់កម្រិត (គឺខិតមកជិតឡាម៉ែល និងបន្ទះឡាម)រួចមកទើបមួលវីសធំបន្តិចម្តងៗ រហូតពិនិត្យឃើញរូបភាព (បើរូបភាពពុំទាន់ច្បាស់ល្អទេ ត្រូវតែប្រើវីសតូចដោយរំកិលតិចៗដើម្បីតម្រូវឱ្យរូបភាពកាន់តែច្បាស់ល្អថែមទៀត)។

**<u>ចំណាំ៖</u>** កម្រិតនៃការពង្រីកសរុបរបស់មីក្រូទស្សន៍ ស្មើនឹងផលគុណនៃការពង្រីករបស់អុបសិចទីប និងការពង្រីករបស់អូគុយលែ។ ***ឧទាហរណ៍៖*** បើយើងពិនិត្យឃើញវត្ថុមួយនៅលើសិលា ដែលយើងប្រើបានប្រើ អូគុយលែមានតួលេខ ឬតម្លៃពង្រីក(10x)និងអុបសិចទីបមានតួលេខ ឬតម្លៃពង្រីក(40x)នោះទំហំរូបភាពដែលយើងមើលឃើញដោយភ្នែករបស់យើងនោះគឺ ចំនួន ៤០០ដង ដែលមានតម្លៃ 10x40 = 400x ។

## ៥. ការសរសេរសន្លឹកកិច្ចការពិសោធន៍

ការបង្រៀនពិសោធន៍ដោយគ្រូបង្គោល

## ៥.១ .ប្រធានបទទី១៖ កំណើនកម្តៅលើពិភពលោក

**១. វត្ថុបំណង៖** នៅពេលចប់មេរៀននេះ សិស្សមានសមត្ថភាព៖

- **វិជ្ជាសម្បទា** រៀបរាប់បានពីមូលហេតុបណ្តាលឱ្យផែនដីឡើងកម្តៅបានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម និងពិសោធន៍ ($CO_2$ )។
- **បំណិនសម្បទា** វិភាគពីកត្តាធ្វើឱ្យផែនដីឡើងកម្តៅបានច្បាស់លាស់តាមរយៈការពិសោធ និងការងារក្រុម។
- **ចរិយាសម្បទា** បណ្តុះមនសិកាចូលរួមសកម្មភាពប្រចាំបានជាប់ជាប្រចាំក្នុងការកាត់បន្ថយការកើនកម្តៅលើផែនដី។

## ២. ខ្លឹមសារមេរៀន

១. ផលផ្ទះកញ្ចក់

២. ប្រភពឧស្ម័នផ្ទះកញ្ចក់

៣. កំណើនផលផ្ទះកញ្ចក់

ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់យ៉ាងច្រើនទៅក្នុងបរិយាកាសបណ្តាលឱ្យសីតុណ្ហភាពមធ្យមរបស់ភពផែនដីកើនឡើង។ ឧស្ម័នផ្ទះកញ្ចក់រួមមាន ឧស្ម័នកាបូនិច មេតាន ក្លរ៉ូភ្លុយអ៊ីរ៉ូកាបួន(CFCs) អូសូន អាសូតអុកស៊ីត និងចំហាយទឹកផងដែរ ដែលបញ្ចេញដោយសកម្មភាពមនុស្សដូចជាចំហេះផូស៊ីលឥន្ធនៈ ការធ្វើកសិកម្ម ម៉ាស៊ីនត្រជាក់ជាដើម។ ឥទ្ធិពលនៃកំណើនកម្តៅផែនដីបណ្តាលឱ្យមានការរលាយនៃទឹកកក ការជន់លិចដីកសិកម្ម អាកាសធាតុប្រែប្រួល និងប៉ះពាល់ដល់សុខភាពរបស់មនុស្ស និងសត្វ។

## ៣. សម្ភារគ្រូវការ

| | |
|---|---|
| - កែវថ្លាធំៗ | - អំពូលពងមាន់ ១០០W |
| - ទឹកខ្មេះ | - សីតុណ្ហមាត្រអេឡិចត្រូនិក |
| - នាឡិកាកំណត់ម៉ោង | - ថង់ប្លាស្ទិច |
| - ទុយោ | - ដង្កៀប |
| - រូឡូខ្សែភ្លើង | - កៅស៊ូ |

## ៤.លំនាំនៃការបង្រៀន

វិធីសាស្ត្របង្រៀនតាមបែបរិះរកដោយប្រើយុទ្ធវិធីៈ វិធីវិទ្យាសាស្ត្រ និងការបញ្ជ្រាប STEM

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| | **ជំហានទី១៖ លំនឹងថ្នាក់(២នាទី)** | |
| ○ ត្រួតពិនិត្យសណ្តាប់ធ្នាប់សិស្ស<br>○ ត្រួតពិនិត្យវត្តមានសិស្ស | រដ្ឋបាលថ្នាក់ | ▪ សិស្សអង្គុយតាមកន្លែងដោយស្ងៀមស្ងាត់<br>▪ សិស្សរាយការណ៍វត្តមាន |
| | **ជំហានទី២៖ រំលឹកមេរៀនចាស់(៥នាទី)** | |
| O តើសារធាតុបំពុលអាកាសមានអ្វីខ្លះ?<br>○ តើសារធាតុបំពុលអាកាសមានប្រភពមកពីណាខ្លះ? | រំលឹកសិស្សអំពីចំណេះដឹងដែលបានរៀនកាលពីពេលមុន។ | ▪ សារធាតុបំពុលអាកាសមានដូចជាភាគល្អិតតូចៗនិងឧស្ម័នពុលដូចជា $CO_2$ $SO_2$ NO, CFCs...។<br>▪ សារធាតុបំពុលអាកាសមានប្រភពពីសកម្មភាពមនុស្សមានដូចជាការប្រើប្រាស់យានយន្ត រោងចក្រឧស្សាហកម្ម ការដុតព្រៃ...និងសកម្មភាពធម្មជាតិដូចជាបន្ទុះភ្នំភ្លើង ។ល។ |
| | **ជំហានទី៣៖ មេរៀនថ្មី(៣៥ នាទី )** | |
| ○ រៀបចំសិស្សជា៤ក្រុម។<br>○ បង្ហាញក្រាបស្តីពីកំណើនសីតុណ្ហភាពផ្ទៃផែនដីបន្ទាប់មកសួរសិស្សថាក្រាបនេះចង់បង្ហាញពីអ្វី?<br>○ ឱ្យសិស្សពិភាក្សាគ្នាកំណត់និយមន័យកំណើនកម្តៅលើផែនដី។ |  <br>ការកើនឡើងកម្តៅលើផែនដីគឺជាកំណើននៃសីតុណ្ហភាពជាមធ្យមនៅលើផែនដី។ | ▪ សិស្សអង្គុយតាមក្រុម<br>▪ សិស្សសង្កេតមើលក្រាប ហើយឆ្លើយថា ក្រាមនេះបង្ហាញពីកំណើនកម្តៅសីតុណ្ហភាពផែនដីឬការកើនឡើងកម្តៅលើផែនដី។<br>▪ សិស្សកំណត់និយមន័យៈ ការកើនឡើងកម្តៅលើផែនដីគឺជាកំណើននៃសីតុណ្ហភាពជាមធ្យមនៅលើផែនដី។ |

<table>
<tr>
<td>ផ្តល់ឱកាសឱ្យសិស្សសួរសំណួរអំពីកំណើនកម្តៅលើផែនដី។ សិស្សអាចសួរសំណួរផ្សេងៗពីគ្នាអំពីកំណើនកម្តៅលើផែនដីប៉ុន្តែគ្រូលើកយកតែសំណួរទាក់ទងនឹងមូលហេតុនៃកំណើនកម្តៅលើផែនដីប៉ុណ្ណោះមកសិក្សាក្នុងម៉ោងនេះហើយសំណួរផ្សេងទៀតនឹងសិក្សានៅពេលក្រោយ។</td>
<td></td>
<td>▪ សិស្សបង្កើតសំណួរមានដូចជា៖ហេតុអ្វីបានជាផែនដីឡើងកម្តៅ? តើការកើនឡើងកម្តៅលើផែនដីបណ្តាលឱ្យមានផលប៉ះពាល់អ្វីខ្លះ? តើមានវិធីសាស្ត្រទប់ស្កាត់អ្វីខ្លះ?</td>
</tr>
<tr>
<td colspan="3"><u>សំណួរគន្លឹះ:</u><br>ហេតុអ្វីបានជាភពផែនដីឡើងកម្តៅ?</td>
</tr>
<tr>
<td>○ ហៅសិស្សឡើងបង្ហាញសម្មតិកម្ម។ បន្ទាប់មកផ្តោតការយកចិត្តទុកដាក់លើឧស្ម័នកាបូនិច ($CO_2$)ជាមូលហេតុនៃកំណើនកម្តៅផែនដីដោយមានពិសោធន៍បង្ហាញ។<br>○ ដឹកនាំសិស្សឱ្យធ្វើការជាក្រុមដើម្បីបង្កើតប្លង់ពិសោធន៍ដោយប្រើប្រាស់ ($CO_2$) មានដូចជា៖<br>- សម្ភារត្រូវការ<br>- របៀបដំឡើងការពិសោធន៍។<br>- របៀបអាន និងកត់ត្រាបម្រែបម្រួលសីតុណ្ហភាពក្នុងរយៈពេល៥នាទី។<br>ហៅសិស្សឱ្យបកស្រាយ</td>
<td>• ការប្រើប្រាស់ថយន្តធ្វើឱ្យផែនដីឡើងកម្តៅ។<br>➢ ដំណើរការពិសោធ<br>១.ដំឡើងឧបករណ៍ដូចបង្ហាញក្នុងរូបខាងក្រោម៖<br>សម្ភារពិសោធជាមួយ $CO_2$<br><br>សម្ភារពិសោធជាមួយខ្យល់</td>
<td>▪ សិស្សបកស្រាយសម្មតិកម្ម<br>▪ សិស្សធ្វើប្លង់ពិសោធ<br>▪ សិស្សបកស្រាយពីដំណើរការពិសោធ</td>
</tr>
<tr>
<td></td>
<td><table>
<tr><td rowspan="2">រយៈពេល</td><td colspan="2">សីតុណ្ហភាព(°C )</td></tr>
<tr><td>ពិសោធន៍ខ្យល់/$CO_2$</td><td>ភាពខុសគ្នានៃសីតុណ្ហភាព (0-5mns )</td></tr>
<tr><td>0នាទី</td><td></td><td></td></tr>
</table></td>
<td>▪ សិស្សស្តាប់ និងកត់ត្រា</td>
</tr>
</table>

<table>
<tr>
<td>○ ហៅតំណាងក្រុមឡើងរាយការណ៍លទ្ធផល។<br>○ សួរសិស្សថា ប្អូនបានរកឃើញអ្វីពីការពិសោធ?<br>○ ឱ្យសិស្សគិតជាក្រុមអំពីប្រភពនៃកំណើនឧស្ម័នកាបូនិច។<br>○ ណែនាំឱ្យសិស្សធ្វើសេចក្ដីសន្និដ្ឋានអំពីមូលហេតុនៃកំណើនកម្ដៅលើផែនដីផ្អែកលើអ្វីដែលបានពិភាក្សា។</td>
<td><table>
<tr><td>១នាទី</td><td></td><td></td></tr>
<tr><td>២នាទី</td><td></td><td></td></tr>
<tr><td>៣នាទី</td><td></td><td></td></tr>
<tr><td>៤នាទី</td><td></td><td></td></tr>
<tr><td>៥នាទី</td><td></td><td></td></tr>
</table>
២. បើកភ្លើងអំពូលក្នុងពេលដំណាលគ្នា។<br>៣. កត់ត្រាកំណើនសីតុណ្ហភាពដោយប្រើប្រាស់តារាងសន្លឹកកិច្ចការខាងក្រោម៖<br>ការវិភាគលទ្ធផល<br>សីតុណ្ហភាពខ្យល់ដែលមានឧស្ម័នកាបូនិចកើនលឿនជាងសិតុណ្ហភាពខ្យល់ធម្មតា។<br>ការសន្និដ្ឋាន<br>កំណើនកម្ដៅលើផែនដីបណ្ដាលមកពីបរិមាណឧស្ម័នផ្ទះកញ្ចក់កើនឡើងដូចជា $CO_2$ ដែលបញ្ចេញដោយសកម្មភាពមនុស្ស (រួមមានចំហេះផូស៊ីលឥន្ធនៈ ការបំផ្លាញព្រៃ...) រាំងស្ទាក់កម្ដៅនៅក្នុងបរិយាកាសផែនដី។</td>
<td>▪ សិស្សបកស្រាយលទ្ធផលនៅលើក្ដារខៀន។<br>▪ សិស្សបកស្រាយ។<br>▪ សិស្សពិភាក្សានិងផ្ដល់យោបល់អំពីប្រភពឧស្ម័នផ្ទះកញ្ចក់។<br>▪ សិស្សធ្វើសេចក្ដីសន្និដ្ឋានអំពីមូលហេតុនៃកំណើនកម្ដៅលើផែនដី។</td>
</tr>
<tr><td colspan="3">ជំហានទី៤៖ ពង្រឹងពុទ្ធិ (៥នាទី)</td></tr>
<tr>
<td>○ ដូចម្ដេចដែលហៅថាការកើនកម្ដៅឡើងលើផែនដី?<br>○ តើកំណើនកម្ដៅលើផែនដីបណ្ដាលមកពីអ្វី?</td>
<td>រំលឹកសិស្សនូវចំណុចសំខាន់ៗដែលបានរៀនថ្ងៃនេះ។</td>
<td>▪ សិស្សឆ្លើយតាមមេរៀនដែលបានរៀនថ្ងៃនេះ។<br>▪ សិស្សឆ្លើយតាមមេរៀនដែលបានរៀនថ្ងៃនេះ។</td>
</tr>
</table>

<table>
<tr><td colspan="3">ជំហានទី ៥៖ បណ្ដាំផ្ញើ/កិច្ចការផ្ទះ (៣នាទី)</td></tr>
<tr>
<td>○ ឱ្យសិស្សប្រាប់ឈ្មោះឧស្ម័នផ្ទះកញ្ចក់ផ្សេងទៀតដែលអាចធ្វើឱ្យផែនដីឡើងកម្ដៅ។</td>
<td>ការផ្ទៀងផ្ទាត់ និងបទពិសោធន៍ជាមួយធម្មជាតិជាក់ស្ដែង។</td>
<td>▪ សិស្សកត់សំណួរដើម្បីឆ្លើយនៅផ្ទះ។</td>
</tr>
</table>

# សន្លឹកកិច្ចការ

សំណួរគន្លឹះ:
ហេតុអ្វីបានជាផែនដីឡើងកម្ដៅ?

១. សម្មតិកម្ម-----------------------------------------------------------------------------------------------------

២. ពិសោធន៍

-សម្ភារត្រូវការ៖ ----------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

-របៀបពិសោធន៍៖ ------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

## ៣. កំណត់ត្រាបម្រែបម្រួលសីតុណ្ហភាព (លទ្ធផល)

| រយៈពេល | សីតុណ្ហភាព ( $^0C$ ) | | |
|---|---|---|---|
| | ពិសោធន៍ ( ខ្យល់ ) | ពិសោធន៍ ( $CO_2$ ) | គម្លាតពី 0min-5min |
| 0 min | | | |
| 1 min | | | |
| 2 min | | | |
| 3 min | | | |
| 4 min | | | |
| 5 min | | | |

## ៤. សេចក្ដីសន្និដ្ឋាន

-------------------------------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

-------------------------------------------------------------------------------------------------------------------

## កំណត់ចំណាំនៅក្នុងមេរៀននេះ ( Lesson Notes )

### ១.ភាពចាំបាច់នៅក្នុងមេរៀន

មេរៀននេះសម្រាប់បង្រៀនសិស្សនៅថ្នាក់ទី៩ផង និងថ្នាក់ទី១២ផង។ ដូច្នេះគ្រូអាចយកមេរៀននេះទៅបង្រៀនសិស្សនៅកម្រិតថ្នាក់ណាមួយក៏បានដោយគ្រាន់កែសម្រួលលំនាំនៃការពិសោធខ្លះប៉ុណ្ណោះ។

សិស្សចាំបាច់ត្រូវមានចំណេះដឹងអំពីសារធាតុបំពុលខ្យល់ ការអានក្រាប ប្រតិកម្មគីមីបង្កើតឧស្ម័នកាបូនិច ម៉ាសមាឌរបស់ឧស្ម័នកាបូនិច និងការគណនារកកំណើនសីតុណ្ហភាព។ សម្រាប់សិស្សថ្នាក់ទី៩ ពួកគេបានសិក្សាអំពីការបំពុលអាកាសរួចហើយ ប៉ុន្តែទាមទារឱ្យគ្រូពន្យល់បន្ថែមអំពីប្រតិកម្មគីមីបង្កើតឧស្ម័នកាបូនិច និងម៉ាសមាឌរបស់វា។

### ២. សម្ភារសម្រាប់ពិសោធន៍

សម្ភារទាំងអស់អាចងាយស្រួលរកទិញបាននៅតាមមូលដ្ឋាន។ សម្ភារទាំងនោះរួមមានកែវថ្លាធំៗ អំពូលពងមាន់១០០W ទឹកខ្មេះ សីតុណ្ហមាត្រអេឡិចត្រូនិក នាឡិកាកំណត់ម៉ោង ថង់ប្លាស្ទិច ទុយោ ដង្កៀប រូឡូ ខ្សែភ្លើង និងកៅស៊ូកង ។

### ៣. ការប្រើសម្ភារ

- គ្រូត្រូវប្រគល់សម្ភារដល់សិស្សដើម្បីរៀបចំការពិសោធដោយខ្លួនឯង។
- គ្រូត្រូវបង្រៀនសិស្សអំពីរបៀបប្រើប្រាស់ឧបករណ៍មុនពេលឱ្យពួកគេធ្វើពិសោធ និងមូលហេតុនៃការប្រើប្រាស់ឧបករណ៍ឱ្យបានល្អិតល្អន់ដើម្បីជៀសវាងកំហុសផ្សេងៗដែលអាចកើតឡើង។
- គ្រូត្រូវណែនាំសិស្សឱ្យបំពេញសន្លឹកកិច្ចការទៅតាមលទ្ធផលដែលទទួលបានពីការធ្វើពិសោធ និងធ្វើការប្រៀបធៀប។

### ៤.ការរិះរកនៅក្នុងមេរៀន

មេរៀននេះធ្វើឱ្យសិស្សមានឱកាសរិះរកឃើញពីមូលហេតុនៃកំណើនកម្ដៅ ដោយសារឧស្ម័នកាបូនិកបានត្រឹមត្រូវតាមរយៈការបង្កើតដំណើរការពិសោធន៍ និងការធ្វើពិសោធន៍ដោយខ្លួនឯង។ សិស្សមានឱកាសគិតពីដំណើរការពិសោធជាក្រុមប្រកបដោយសេចក្ដីរីករាយ និងមានបំណិនទាក់ទងនិងវិទ្យាសាស្ត្រដទៃទៀត បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា ( STEM )។

### ៥. វាយតម្លៃសិស្ស

- សិស្សធ្វើពិសោធបានយ៉ាងសកម្ម និងដំណើរការទៅយ៉ាងរលូន
- ការបំពេញសន្លឹកកិច្ចការបានត្រឹមត្រូវ
- កត់ត្រាមេរៀនក្នុងសៀវភៅបានរៀបរយល្អ។

## ៥.២ ប្រធានបទទី២ ៖ ការបំពុល ឬ កខ្វក់

**១. វត្ថុបំណង៖** នៅពេលចប់មេរៀននេះសិស្សអាច៖

- **វិជ្ជាសម្បទា៖** ពណ៌នាពីការបំពុលខ្យល់ដោយភាគល្អិតនៅក្នុងខ្យល់បានត្រឹមត្រូវតាមរយៈការពិភាក្សាក្រុម
- **បំណិនសម្បទា ៖** វិភាគកម្រិតនៃការបំពុលខ្យល់ដោយភាគល្អិតតាមរយៈការពិសោធន៍ជាក់លាក់
- **ចរិយាសម្បទា ៖** ចូលរួមសកម្មភាពប្រចាំថ្ងៃក្នុងការកាត់បន្ថយការបំពុលខ្យល់ និងការពារសុខភាពពីការបំពុលខ្យល់។

## ២. ខ្លឹមសារ (ការបំពុលខ្យល់)

ភាគល្អិតបំពុលខ្យល់មានច្រើនប្រភេទ ហើយភាគល្អិតក៏ជាភ្នាក់ងារបំពុលខ្យល់មួយដែរ។ ភាគល្អិតទាំងនោះមានរឹង និងរាវ។ ភាគល្អិតមានទំហំធំជាង ១០μm អាចស្ថិតនៅមណ្ឌលអាកាសរចល់នៃបរិយាកាស១ទៅ២ថ្ងៃ ភាគល្អិតមានទំហំពី ១ ទៅ ១០μm អាចស្ថិតក្នុងមណ្ឌលអាកាសរចល់ ២ ទៅ ៣ថ្ងៃ ហើយភាគល្អិតមានទំហំតូចជាង ១ μm អាចស្ថិតនៅក្នុងបរិយាកាស ១ ទៅ ២ សប្តាហ៍ និងអាចដល់៥ឆ្នាំនៅក្នុងមណ្ឌលអាកាសស្ងប់។ សកម្មភាពមនុស្សរួមមានចំហេះផូស៊ីលឥន្ធនៈ ការដឹកជញ្ជូនដោយយានយន្ត ការដ្ឋានសំណង់... បានបញ្ចេញភាគល្អិតទៅក្នុងខ្យល់ ។ ភាគល្អិតតូចជាង ២.៥ μm អាចប៉ះពាល់ដល់សួត បំពង់ក និងច្រមុះ...។

## ៣. សម្ភារឧបទេស

- គំរបកេសក្រដាស A4
- កញ្ចក់ឡាម
- មីក្រូទស្សន៍
- ធុងទឹក
- ស្កុតថ្លា (19mm x 32.9m ផលិតនៅ USA)
- ក្រដាសមានក្រិត
- កន្ត្រៃ
- ក្រដាសអនាម័យ

## ៤.លំនាំនៃការបង្រៀន

**វិធីសាស្ត្របង្រៀនតាមបែបរិះរកដោយយុទ្ធវិធី 5E**

| សកម្មភាពគ្រូ | ខ្លឹមសារមេរៀន | សកម្មភាពសិស្ស |
|---|---|---|
| **ជំហានទី១៖ លំនឹងថ្នាក់ (៣នាទី)** | | |
| ○ត្រួតពិនិត្យសណ្តាប់ធ្នាប់សិស្ស<br>○ត្រួតពិនិត្យវត្តមាន | ពង្រឹងរដ្ឋបាលថ្នាក់ | ▪ សិស្សអង្គុយតាមកន្លែង ដោយស្ងៀមស្ងាត់<br>▪ សិស្សរាយការណ៍វត្តមាន |
| **ជំហានទី២៖ រំលឹកមេរៀនចាស់ (៥នាទី)** | | |
| ចូលរួម (Engage)<br>○ ហេតុអ្វីបានជាចំនួនប្រជាជននៅក្នុងទីក្រុងភ្នំពេញកើន ឡើងឆាប់រហ័ស?<br>○ តើកំណើនចំនួនប្រជាជន មានទំនាក់ទំនងនឹងការបំពុល ដូចម្តេចខ្លះ?<br>○ តើភ្នាក់ងារនៃការបំពុលខ្យល់មានអ្វីខ្លះ? | រំលឹកសិស្សអំពីចំណេះដឹងដែលមានរៀនកាលពីពេលមុន។ | ▪ ដោយសារមានឱកាសការងារល្អៗ ការសិក្សា និងសេវាសុខភាពល្អប្រសើរ ភាពស៊ីវិល័យ...។<br>▪ មនុស្សច្រើនបញ្ចេញសារជាតុពុលកាន់ច្រើនទៅក្នុងខ្យល់ ទឹក និងដី។<br>▪ ភាគល្អិតតូចៗ និងឧស្ម័នពុលដូចជា $CO_2$, $SO_2$, NO, CFCs...។ |

## ជំហានទី ៣៖ មេរៀនថ្ងៃនេះ (៣៥ នា ទី)

**សំណួរគន្លឹះ:**

**តើការបំពុលខ្យល់ដោយភាគល្អិតនៅតាមដងផ្លូវ និងក្នុងទីធ្លាសាលារៀនមានកម្រិតខុសគ្នាដូចម្តេចខ្លះ?**

| | | |
|---|---|---|
| ○ចែកសិស្សជាក្រុមតូចៗ និង ប្រគល់សន្លឹកកិច្ចការ។<br>○ឱ្យសិស្សបង្កើតសម្មតិកម្មអំពី កម្រិតនៃការបំពុលដោយភាគល្អិតរវាងនៅតាមដងផ្លូវ និង ក្នុងទីធ្លាសាលារៀន។<br><br>រុករក (Explore)<br>○ប្រគល់សម្ភារពិសោធន៍ និង ណែនាំសិស្សខ្លះៗអំពីការប្រើប្រាស់សម្ភារ និងប្រមូលទិន្នន័យ។<br>○ប្រាប់សិស្សឱ្យពិភាក្សាគ្នាអំពីការច្នៃប្រឌិតបង្កើតឧបករណ៍ វិធីប្រើប្រាស់ ការជ្រើសរើស ទីតាំង និងវិភាគទិន្នន័យ៖ តើត្រូវបង្កើត | **១. ការបំពុលខ្យល់**<br>ភ្នាក់ងារបំពុលខ្យល់មានច្រើន ប្រភេទ ហើយភាគល្អិតក៏ជាភ្នាក់ងារបំពុលខ្យល់មួយដែរ។ ភាគល្អិតទាំងនោះមានរឹង និងរាវ។ ភាគល្អិតមានទំហំធំជាង១០ µm អាចស្ថិតនៅក្នុងមណ្ឌលអាកាសរចល់នៃបរិយាកាស ១ទៅ២ថ្ងៃភាគល្អិតមានទំហំពី១ ទៅ ១០ µm អាចស្ថិតនៅក្នុងមណ្ឌលអាកាសរចល់ ២ ទៅ ៣ថ្ងៃ ហើយភាគល្អិតមានទំហំតូចជាង១µm អាចស្ថិតនៅក្នុងបរិយាកាស១ទៅ២ សប្តាហ៍ និងអាចដល់៥ឆ្នាំនៅ ក្នុងមណ្ឌលអាកាសស្ងប់ ។<br>សកម្មភាពមនុស្សរួមមាន៖ ចំហេះផូស៊ីលឥន្ធនៈ ការដឹកជញ្ជូនដោយយានយន្ត ការដ្ឋាន សំណង់... បានបញ្ចេញភាគល្អិត ទៅក្នុងខ្យល់។ ភាគល្អិតតូចជាង ២.៥ um អាចប៉ះពាល់ដល់សួត បំពង់ក និងច្រមុះ...។<br>**ដំណើរការពិសោធ៖**<br>➢ ជ្រើសរើសទីតាំង<br>➢ បិតស្កុតជាមួយនឹងគម្របកេសក្រដាស A4<br>➢ ឈរបេក់គម្របកេសក្រដាស A4 ឡើងចុះឱ្យបាន៩០ដឺក្រេ ចំនួន ២០០ដងក្នុងមួយកន្លែង<br>➢ កាត់ស្កុតបិតភ្ជាប់នឹងសន្លឹកផ្លាស្ទិចថ្លា ហើយទុកក្នុងថង់ស្អាតមួយ។ | ▪ សិស្សស្វែងរកសមាជិកក្រុម និងទទួលសន្លឹកកិច្ចការ។<br>▪ សិស្សបង្កើតសម្មតិកម្ម<br><br>▪ សិស្សទទួលសម្ភារពិសោធពីគ្រូ និងស្តាប់ការណែនាំ<br><br>▪ សិស្សពិភាក្សាគ្នាអំពីការ |

| | | |
|---|---|---|
| និងប្រើប្រាស់ ឧបករណ៍ដូចម្ដេច? តើគួរ ជ្រើសរើសទីតាំងដូចម្ដេច? បានទិន្នន័យហើយត្រូវវិភាគ ដូចម្ដេច?<br>○ បន្ទាប់មក ត្រូវធ្វើការសម្របសម្រួលដំណើរការពិសោធន៍<br>○ ឱ្យសិស្សចុះទៅប្រមូល ទិន្នន័យតាមទីតាំងដែលបាន ជ្រើសរើស។<br>ពន្យល់ (Explain)<br>○ ហៅតំណាងក្រុមនីមួយៗឱ្យឡើងបកស្រាយលទ្ធផល និងធ្វើសេចក្ដីសន្និដ្ឋាន។<br>ពង្រីកគំនិត (Elaborate/Extend)<br>○ បន្ទាប់មកសួរសិស្ស៖<br>១. តើទំហំភាគល្អិតមានទំនាក់ទំនងដូចម្ដេចជាមួយនឹងរយៈពេលអណ្ដែតនៅក្នុងខ្យល់? ២. តើភាគល្អិតផ្ដល់ផលប៉ះ ពាល់ចំពោះសុខភាពដូចម្ដេចខ្លះ? ៣. តើយើងគួរធ្វើដូចម្ដេច ដើម្បីការពារខ្លួនពីការបំពុល ខ្យល់ដោយភាគល្អិត?<br>○ បង្ហាញសិស្សអំពីព័ត៌មាន ទំហំភាគល្អិត រយៈពេល ស្ថិតនៅក្នុងខ្យល់ និងផលប៉ះពាល់ចំពោះសុខភាព។ | ➢ កាត់ស្លុតដែលមានភាគល្អិតនូវទំហំ ២៥mm² ចំនួន៤ ប្រឡោះ (សរុប១០០mm²) ដោយប្រើប្រាស់ក្រដាសមីលីម៉ែត្រ។<br>➢ រាប់ចំនួនភាគល្អិតដោយ សង្កេតក្នុងមីក្រូទស្សន៍(កម្រិតពង្រីក 10 x 4)។ | ផលិតឧបករណ៍ ទីតាំង វិធីប្រមូលទិន្នន័យ និងការវិភាគទិន្នន័យ។<br>▪ សិស្សចុះទៅប្រមូល និង វិភាគទិន្នន័យ។<br>▪ តំណាងក្រុមឡើងបកស្រាយលទ្ធផលស្រាវជ្រាវ<br><br>▪ **ការសន្និដ្ឋាន៖** កម្រិតនៃការបំពុលខ្យល់ដោយភាគល្អិត នៅតាមដងផ្លូវខ្លាំងជាងនៅ ក្នុងទីធ្លាសាលារៀន។<br>▪ ភាគល្អិតកាន់តែតូចអាចអណ្ដែតនៅក្នុងខ្យល់បានកាន់តែយូរ។<br>▪ ភាគល្អិតអាចប៉ះពាល់ដល់សួត បំពង់ក និងច្រមុះ...។<br>▪ ដើម្បីការពារខ្លួនពីការបំពុលខ្យល់ដោយភាគល្អិត គឺត្រូវពាក់ម៉ាស់ការពារ ដាំដើមឈើ ជៀសវាងនៅឱ្យ ឆ្ងាយពីផ្លូវសារធារណៈ...។<br>▪ សិស្សឆ្លើយបញ្ហា។ |

| ជំហានទី ៤៖ ពង្រឹងពុទ្ធិ ( ៥ នាទី ) | | |
|---|---|---|
| វាយតម្លៃ ( Evaluate )<br>○ គ្រូចែកក្រដាសតេស្តឱ្យសិស្ស រយៈពេលពេល៥នាទី<br>○ គ្រូត្រួតពិនិត្យកិច្ចការសិស្ស និង ផ្តល់ចម្លើយត្រឹមត្រូវ។ | រំលឹកសិស្សនូវចំណុចសំខាន់ៗ ដែលបានរៀនថ្ងៃនេះ។ | ▪ សិស្សទទួលយកក្រដាស និង ឆ្លើយសំណួរ<br>▪ សិស្សស្តាប់ និងកត់ត្រា |
| **ជំហានទី ៥៖ បណ្តាំផ្ញើ ឬកិច្ចការផ្ទះ (២ នាទី)** | | |
| ○ ចូរធ្វើពិសោធខ្លួនឯងនៅផ្ទះ បន្ថែមទៀតទៅតាមលក្ខខណ្ឌនៃពេលវេលាខុសៗគ្នា និងតាមថ្ងៃក្នុងសប្តាហ៍។ | | ▪ សិស្សកត់សំណួរដើម្បីឆ្លើយនៅផ្ទះ។ |

# សន្លឹកកិច្ចការ

**សំណួរគន្លឹះ**

តើការបំពុលខ្យល់ដោយភាគល្អិតនៅតាមដងផ្លូវ និងក្នុងទីធ្លាសាលារៀនមានកម្រិតខុសគ្នាដូចម្តេចខ្លះ?

១. សម្មតិកម្ម៖

២. ប្លង់ពិសោធន៍៖

៣. លទ្ធផល៖

៤. សន្និដ្ឋាន៖

## តេស្តត្រួតពិនិត្យ

១. តើការបំពុលខ្យល់ដោយភាគល្អិតនៅទីតាំងខាងក្រោមមួយណាមានកម្រិតខ្ពស់ជាង?

☐ ក.ដងផ្លូវ ☐ ខ.ទីធ្លាសាលា

២. ទំហំភាគល្អិតកាន់តែធំ អាចស្ថិតក្នុងខ្យល់កាន់តែយូរ។

☐ ក.ត្រឹមត្រូវ ☐ ខ.មិនត្រឹមត្រូវ

៣. ភាគល្អិតកាន់តែតូចប៉ះពាល់សុខភាពកាន់តែខ្លាំង។

☐ ក.ត្រឹមត្រូវ ☐ ខ.មិនត្រឹមត្រូវ

៤. តើគួរធ្វើយ៉ាងដូចម្តេច ដើម្បីការពារសុខភាពពីការបំពុលខ្យល់ដោយភាគល្អិត?

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

--------------------------------------------------------------------------------------------------------

## ៦. វិធីសាស្ត្របង្រៀន និងរៀនពិសោធន៍

សម្រាប់ការបង្ហាញពិសោធន៍ដោយគ្រូបង្គោលមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា ទៅលើប្រធានបទទាំងពីរខាងលើនេះ គឺប្រធានបទទី១ ប្រើប្រាស់ការបង្រៀន និងរៀនតាមបែបរិះរក ជាមួយវិធីវិទ្យាសាស្ត្រដែលមានជំហាន សំខាន់ៗរួមមាន (១) ការកំណត់បញ្ហា (២) ការបង្កើតសម្មតិកម្ម (៣) ការធ្វើតេស្តសម្មតិកម្ម (ការធ្វើពិសោធ) (៤) លទ្ធផល និង(៥) ការវិភាគ និងសន្និដ្ឋាន ហើយចំពោះប្រធានបទទី២វិញ គឺប្រើប្រាស់វិធីបង្រៀន និងរៀន តាមគំរូ ៥E ដែលរួមមាន (១) ចូលរួម/ទាញចំណាប់អារម្មណ៍ (Engage) (២) រុករក (Explore) (៣) ពន្យល់ (Explain) (៤) ពង្រីកបន្ថែម (Elaborate) និង(៥) វាយតម្លៃ (Evaluate)។

## ៧. សារៈប្រយោជន៍នៃសម្ភារឧបទេស

សម្ភារឧបទេស គឺជាអ្នកនាំសារពីគ្រូទៅឱ្យសិស្សក្នុងថ្នាក់។ ដូចច្នេះគ្រូបង្រៀនអាចសម្រេចវត្ថុបំណង មេរៀនបានយ៉ាងមានប្រសិទ្ធភាពតាមរយៈការប្រើប្រាស់សម្ភារឧបទេសដែលសមស្រប។

សម្ភារឧបទេសមានតួនាទី៖

- ធ្វើឱ្យការបង្រៀនប្រព្រឹត្តទៅបានល្អ បង្កើតរូបបារម្មណ៍ បង្កើតគំនិតថ្មីងាយស្រួលក្នុងការបង្រៀន និងរៀន
- ផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត
- ធ្វើអ្វីដែលអរូបីឱ្យមានលក្ខណៈរូបី ពង្រឹងចំណេះដឹងបណ្តុះស្មារតីសិស្ស
- ធ្វើឱ្យសម្រេចវត្ថុបំណងមេរៀន
- ធ្វើឱ្យថ្នាក់រៀនមានលក្ខណៈសកម្ម និងមានភាពរស់រវើកដោយសិស្សបានសង្កេតជាក់ស្តែង វិភាគ សំយោគដោយខ្លួនឯង
- វាជាវិធីធ្វើឱ្យសិស្សចងចាំបានយូរ និងមានចំណូលចិត្តក្នុងការសិក្សា
- ដើម្បីឱ្យខ្លឹមសាមេរៀនកាន់តែច្បាស់លាស់និងងាយយល់

# ឯកសារយោង


១.វិទ្យាស្ថានជាតិអប់រំ. (២០១៩). សៀវភៅវិធីសាស្ត្របង្រៀនសម្រាប់ការបណ្តុះបណ្តាល។

២.ក្រសួងអប់រំ យុវជន និងកីឡា (២០១៩) សៀវភៅសិក្សាគោលផែនដី និងបរិស្ថានវិទ្យាថ្នាក់ទី១០ ទី១១ ទី១២.

៣.កម្រងឯកសាររៀបចំដោយក្រុមការងារគម្រោង SIMSEC-វិទ្យាស្ថានជាតិអប់រំ (២០១៣)សៀវភៅការអនុវត្តគោលសិស្សមជ្ឈមណ្ឌលលើមុខវិជ្ជាវិទ្យាសាស្ត្រ។

៤.សៀវភៅណែនាំស្តីពីឧបករណ៍ពិសោធមន្ទីរពិសោធវិទ្យាសាស្ត្រ (២០១២)។

៥.វិទ្យាស្ថានជាតិអប់រំ (២០០៥). សៀវភៅណែនាំស្តីពីការប្រើប្រាស់សម្ភារពិសោធន៍។